ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

# ភាពជាដៃគូរវាងកម្ពុជា-អ.ស.ប នឹងត្រូវបានពង្រឹងបន្ថែមទៀត

******

នៅក្នុងឱកាសនៃការជួបជំរាបលារបស់លោកស្រី Claire Van der Vaeren តំណាងកម្មវិធីអភិវឌ្ឍន៍ អ.ស.ប ប្រចាំកម្ពុជា (UNDP Resident Representative) និងជាអ្នកសម្របសម្រួលប្រព័ន្ធអ.ស.ប នៅកម្ពុជា (UN Resident Coordinator) នៅព្រឹកថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសម្តែងការអបអរសាទរចំពោះជោគជ័យនៃបេសកកម្ម និងបានកត់សម្គាល់ពីតួនាទីដឹកនាំទីភ្នាក់ងារអ.ស.ប នៅកម្ពុជា របស់លោកស្រី។ **ឯកឧត្តម** បានថ្លែងអំណរគុណចំពោះការខិតខំ និងការលះបង់ផ្ទាល់របស់លោកស្រី ក្នុងការពង្រឹងភាពជាដៃគូរវាងបណ្តាទីភ្នាក់ងារអ.ស.ប និងរាជរដ្ឋាភិបាល ហើយបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលការងារដែលសម្រេចបាន នៅក្នុងរយៈកាល៥ឆ្នាំនៃអាណត្តិការងាររបស់លោកស្រីនៅកម្ពុជា។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ក្នុងឋានៈជាដៃគូដ៏ជិតស្និទ្ធ ក្រុមការងារអ.ស.ប នៅកម្ពុជាតាមរយៈ "ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ" បានរួមវិភាគទានដ៏សំខាន់ដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ការអភិវឌ្ឍសង្គម កិច្ចគាំពារសង្គម ការអភិវឌ្ឍធនធានមនុស្ស អភិបាលកិច្ចល្អ និងសិទ្ធិមនុស្ស ហើយនិងក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ សកម្មភាពមនុស្សធម៌ដូចជា ការបោសសំអាតមីន និងការចូលរួមរបស់កម្ពុជានៅក្នុងបេសកកម្មរក្សាសន្តិភាពពិភពលោករបស់អ.ស.ប ក៏ដូចជាការគាំទ្រដល់ការរីកចម្រើនប្រកបដោយសមធម៌និងបរិយាបន្ននៅកម្ពុជា។

ក្នុងឋានៈឯកឧត្តមជាប្រធានគណៈកម្មាធិការសម្របសម្រួលបេសកកម្មរក្សាសន្តិភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជំរាបជូនលោកស្រីអំពីការចូលរួមរបស់កម្ពុជា នៅក្នុងជោគជ័យនៃបេសកកម្មរក្សាសន្តិភាពអ.ស.ប នៅតាមបណ្តាតំបន់នានារបស់ពិភពលោក ហើយនិងការសោកស្តាយចំពោះការបាត់បង់ជីវិតរបស់ក្រុមទាហានមួកខៀវ នៅក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ជំនួបកាលពីម្សិលមិញ រវាង**សម្តេចតេជោនាយករដ្ឋមន្ត្រី** និងសមាជិករាជរដ្ឋាភិបាល ជាមួយក្រុមភ្នាក់ងារអ.ស.ប បានបើកឡើងនូវទម្រង់ថ្មីមួយនៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជាជាមួយអ.ស.ប ដែលកាន់តែមានភាពអន្តរកម្មខ្លាំងជាងមុន។ **ឯកឧត្តម**បានសំដែងក្តីជឿជាក់ថាការពិភាក្សានោះបានផ្តល់លទ្ធផលប្រកបដោយផ្លែផ្កា ពិសេសលើការផ្គត់ផ្គង់ម្ហូបអាហារ បញ្ហាយុវជន និងការងារ និងការគាំពារផ្នែកសង្គម ហើយនឹងផ្តល់ផលវិជ្ជមានដល់ដំណើរការនៃទំនាក់ទំនងភាពជាដៃគូរវាងរាជរដ្ឋាភិបាល-ក្រុមទីភ្នាក់ងារអ.ស.ប ដើម្បីភាពល្អប្រសើររបស់ប្រទេស និងប្រជាជនកម្ពុជា។

នៅក្នុងជំនួបនេះ លោកស្រី Claire Van der Vaeren បានសម្តែងការរីករាយពេញចិត្ត ចំពោះការបំពេញការងាររបស់លោកស្រីនៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល៥ឆ្នាំ និងបានវាយតម្លៃខ្ពស់ចំពោះ

ការរីកចំរើននៅលើវិស័យជាច្រើនដែលកម្ពុជាសម្រេចបាន ពិសេសគឺនៅលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការរីកចម្រើនផ្នែកសេដ្ឋកិច្ច ដែលធ្វើឲ្យប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់ជាប្រទេសចំណូលមធ្យមកំរិតទាប។

**លោកស្រី** បានវាយតម្លៃខ្ពស់ចំពោះការចូលរួមយ៉ាងសកម្មរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងបេសកកម្មរក្សាសន្តិភាពរបស់អ.ស.ប និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងបណ្តាស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដែលបានផ្តល់កិច្ចសហការដ៏សកម្ម និងការជួយសម្រួលគ្រប់បែបយ៉ាងដល់ក្រុមការងារលោកស្រី ក៏ដូចជាភ្នាក់ងារអ.ស.បដ៏ទៃទៀត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** និងលោកស្រី Claire Van der Vaeren បានពិភាក្សាផ្លាស់ប្តូរយោបល់គ្នាពីការបន្តពង្រឹងបន្ថែមទៀតនូវភាពជាដៃគូដ៏ជិតស្និទ្ធរវាងរាជរដ្ឋាភិបាល និងបណ្តាទីភ្នាក់ងារអ.ស.ប ប្រចាំកម្ពុជា។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃ ព្រហស្បត៍ ០៨ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៨